**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

********

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

ល.ត/លេខ ០២.១០៦/១២ គ.ជ.ប.អគ្គ.ពស

រាជធានីភ្នំពេញ ថ្ងៃទី 18 ខែកុម្ភៈ ឆ្នាំ២០១២

## លទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣ នាថ្ងៃអាទិត្យ ទី២៩ ខែមករា ឆ្នាំ២០១២

នៅថ្ងៃសៅរ៍ ទី១៨ ខែកុម្ភៈ ឆ្នាំ២០១២ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បានចេញសេចក្តីសម្រេចចំនួន ៣ ទី១ សេចក្តីសម្រេចលេខ ១០៤/១២ គ.ជ.ប.ស.ស.រ ស្តីពីការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣ ឆ្នាំ២០១២ ទី២ សេចក្តីសម្រេចលេខ ១០៥/១២ គ.ជ.ប.ស.ស.រ ស្តីពីការកំណត់បែងចែកអាសនៈ សម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតតាមមណ្ឌលភូមិភាគ និងទី៣ សេចក្តីសម្រេចលេខ ១១១/១២ គ.ជ.ប.ស.ស.រ ស្តីពីការប្រកាសបេក្ខជនជាប់ឆ្នោតជាសមាជិកព្រឹទ្ធសភា ។

ខាងក្រោមគឺជាតារាងសម្លេងឆ្នោត និងចំនួនអាសនៈដែលគណបក្សនយោបាយនីមួយៗទទួលបាន នៅតាមមណ្ឌលភូមិភាគនីមួយៗ ៖

| មណ្ឌលភូមិភាគ | រាជធានី ខេត្ត | អាសនៈសរុប | គណបក្សប្រជាជនកម្ពុជា | | គណបក្ស សម រង្ស៊ី | |
|---|---|---|---|---|---|---|
| | | | សម្លេងឆ្នោត | អាសនៈទទួលបាន | សម្លេងឆ្នោត | អាសនៈទទួលបាន |
| មណ្ឌលភូមិភាគទី ១ | រាជធានីភ្នំពេញ | 6 | 533 | 4 | 285 | 2 |
| មណ្ឌលភូមិភាគទី ២ | កំពង់ចាម | 8 | 1,007 | 6 | 355 | 2 |
| មណ្ឌលភូមិភាគទី ៣ | កណ្តាល | 5 | 718 | 4 | 203 | 1 |
| មណ្ឌលភូមិភាគទី ៤ | បាត់ដំបង បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ និងប៉ៃលិន | 10 | 1,670 | 8 | 479 | 2 |
| មណ្ឌលភូមិភាគទី ៥ | តាកែវ កំពត និងកែប | 7 | 1,062 | 6 | 252 | 1 |
| មណ្ឌលភូមិភាគទី ៦ | ព្រៃវែង និងស្វាយរៀង | 7 | 1,146 | 6 | 273 | 1 |
| មណ្ឌលភូមិភាគទី ៧ | កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ កោះកុង និងព្រះសីហនុ | 8 | 1,396 | 7 | 317 | 1 |
| មណ្ឌលភូមិភាគទី ៨ | កំពង់ធំ ព្រះវិហារ ក្រចេះ ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី | 6 | 1,348 | 5 | 339 | 1 |
| សរុបរួម | | 57 | 8,880 | 46 | 2,503 | 11 |

សរុបបេក្ខជនជាប់ឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣នេះ មាន ៥៧រូប ។

ព័ត៌មានលំអិតទាក់ទងនឹងសេចក្តីសម្រេចខាងលើ សូមចូលមើលគេហទំព័រ គ.ជ.ប ដែលមាន អាសយដ្ឋាន www.necelect.org.kh ។

ព័ត៌មានបន្ថែមទំនាក់ទំនង ៖ ០២៣ ២១៨ ៣៧៨ / ០១២ ៨៥៥ ០១៨ ; E-mail: necinfo@forum.org.kh ; www.necelect.org.kh